# អង្គបុរេជំនុំជម្រះជំទាស់បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ទាក់ទិននឹងការឃុំខ្លួនបណ្តោះអាសន្ន

***ដោយ ឡូរ៉ា ម៉ាក់ដូណល់***

***ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩***

*ប្រែសម្រួលដោយ ទែន សុខស្រីនិត*

*នៅចំពោះមុខអ្នកតាមដានបីនាក់នៅសាលសវនាការ និងមេធាវីមួយចំនួនតូចនៅក្នុងបន្ទប់សវនាការ លោកប្រធានចៅក្រមអង្គបុរេជំនុំជម្រះ ប្រាក់ គឹមសាន បានប្រកាសសេចក្តីជំទាស់ប្រឆាំងនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ទាក់ទិននឹងដីការបស់សហចៅក្រមស៊ើបអង្កេតដែលសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង សារី ដែលចេញកាលពីខែវិច្ឆិកា ឆ្នាំ២០០៨។ បណ្តឹងឧទ្ធរណ៍ត្រូវបានសម្រេចដោយផ្អែកលើការដាក់សេចក្តីសន្និដ្ឋានជាលាយល័ក្ខអក្សរនិងសវនាការ ដែលបានធ្វើឡើងកាលពីខែកុម្ភៈ និងមេសា ឆ្នាំ២០០៩ ។*

*បណ្តឹងឧទ្ធរណ៍របស់ អៀង សារី បានស្នើសុំឲ្យចៅក្រមអង្គបុរេជំនុំជម្រះច្រានចោលដីការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន ដោយអនុញ្ញាតឲ្យមានការដោះលែង អៀង សារី ឲ្យនៅក្រៅឃុំ ឬដោយផ្លាស់ប្តូរស្ថានភាពឃុំខ្លួនមកជាការឃុំខ្លួនក្នុងផ្ទះវិញ ។*

*យោងតាមវិធានផ្ទៃក្នុង៦៣របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហចៅក្រមស៊ើបអង្កេតមានសិទ្ធិចេញដីការឃុំខ្លួនបណ្តោះអាសន្ន នៅពេលដែល«មានមូលហេតុច្បាស់លាស់ដែលជឿថា ជនជាប់ចោទអាចនឹងបានប្រព្រឹត្តឧក្រិដ្ឋកម្មពិតមែន» និងនៅពេលដែលការឃុំខ្លួនក្លាយជា«វិធានការណ៍ដ៏មានប្រយោជន៍» ដើម្បីរារាំងជនជាប់ចោទមិនឲ្យធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងសាក្សី ឬអ្នកចូលដៃប្រព្រឹត្តឧក្រិដ្ឋកម្ម និងដើម្បីរក្សានិងការពារសំណុំឯកសារ ធានាឲ្យបាននូវវត្តមានចូលរួមរបស់ជនជាប់ចោទ ការពារជនជាប់ចោទ ឬ«ថែរក្សាសណ្តាប់ធ្នាប់សាធារណៈ» ។*

*ក្នុងបណ្តឹងឧទ្ធរណ៍នេះ មេធាវីរបស់ អៀង សារី បានអះអាងថា ថ្វីបើមានមូលហេតុច្បាស់លាស់ដែលរកឃើញសម្រាប់ការឃុំខ្លួនលើកដំបូងក៏ដោយ ក៏ការបង្ហាញពីភស្តុតាងដែលមានកម្រិតជឿជាក់ខ្ពស់ គឺ*

ពិតជាមានសារសំខាន់ក្នុងការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន ។ លោកប្រធានចៅក្រមរបស់អង្គបុរេជំនុំជម្រះបានច្រានចោលការអះអាងនេះដោយមានប្រសាសន៍ថា សហចៅក្រមស៊ើបអង្កេតពិតជាបានរកឃើញមូលហេតុច្បាស់លាស់ដែលគួរឲ្យជឿថា អៀង សារី ពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់នោះពិតមែន ។ ហើយប្រសិនបើភស្តុតាងដាក់បន្ទុកត្រូវបានដាក់បន្ថែមចូលទៅក្នុងសំណុំរឿងនោះ ហេតុផលទាំងអស់នេះគឺជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ការឃុំខ្លួនក្នុងរយៈពេលដំណើររបស់អង្គបុរេជំនុំជម្រះពេញតែម្តង ។ លោកប្រធានបានកត់សម្គាល់ឃើញថា ជាក់ស្តែង ភស្តុតាងដាក់បន្ទុកជាច្រើន ត្រូវបានដាក់បន្ថែមចូលទៅក្នុងសំណុំរឿងតាំងពីដីការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានសម្រេចមកម្ល៉េះ ។

ក្នុងការជំទាស់ទាក់ទិននឹងស្ថានភាពឃុំខ្លួនរបស់ អៀង សារី និងការស្នើរសុំឲ្យមានការឃុំខ្លួនក្នុងផ្ទះវិញនោះ លោកមេធាវីរបស់ អៀង សារី បានអះអាងថា ដោយសារតែកូនក្តីរបស់លោកមានអាយុ៨៣ឆ្នាំ ហើយប្រពន្ធរបស់កូនក្តីលោកក៏ជាប់ឃុំទៀត នោះកូនក្តីរបស់លោកមិនអាចរត់គេចខ្លួនបានទេ ។ លោកប្រធានបានច្រានចោលសេចក្តីអះអាងនេះ ដោយលើកហេតុផលថា គ្មានភស្តុតាងណាដែលថែងថា ជនជាប់ចោទដែលមានអាយុ៨៣ឆ្នាំមិនអាចធ្វើដំណើរបានទេ ហើយអង្គជំនុំជម្រះបានចាត់ទុកការឃុំខ្លួនរបស់ប្រពន្ធ អៀង សារី ជាកត្តាទម្ងន់ទោសជាជាងកត្តាសម្រាលទោស ។

លោកប្រធានអង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា ភស្តុតាងដែលរកឃើញនាពេលថ្មីៗនេះបង្ហាញថា មាន«ភាពតានតឹងខ្លាំង» នៅក្នុងសង្គមកម្ពុជា និងការផ្លាស់ប្តូរទស្សនៈរបស់សាធារណជនមកលើ អៀង សារី ដូច្នេះហើយការឃុំខ្លួនគឺពិតជាមានសារសំខាន់ដើម្បីការពារពីសុវត្ថិភាពរបស់ជនជាប់ចោទ និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ។ បន្ថែមលើនេះ ចៅក្រមបានសម្រេចថា ការឃុំខ្លួនគឺនៅតែមានសារសំខាន់ក្នុងការធានាឲ្យបាននូវវត្តមានចូលរួមដំណើរការនីតិវិធីរបស់ អៀង សារី ។

ជាចុងបញ្ចប់ លោកប្រធានបានកត់សម្គាលល់ឃើញថា ការស៊ើបអង្កេតបានដំណើរការទៅមុខយ៉ាងលឿនដោយគម្រូវទៅតាមបទដ្ឋានអន្តរជាតិទាក់ទិននឹងភាពច្បាស់លាស់ត្រឹមត្រូវ ។ ហេតុដូច្នេះសិទ្ធិមនុស្សរបស់ អៀង សារី កំពុងតែត្រូវបានគោរព បើទោះបីជា អៀង សារី ត្រូវបានឃុំខ្លួន ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាំងពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ក៏ដោយ ។

អៀង សារី ទទួលរងបទចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ។ ក្នុងអំឡុងរបបខ្មែរក្រហម អៀង សារី គឺជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងជាសមាជិកជាន់ខ្ពស់របស់បក្សកុម្មុនីស្តកម្ពុជា ។